ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...១៦៤...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកាត់ផ្ទៃដីសរុបទំហំ ២៤០ ហិកតា នៅឃុំដាក់ដាំ ស្រុកអូររាំង ឃុំគ្រង់តេះ ស្រុកពេជ្រាដា និងឃុំស្រែហ៊ុយ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដែនជម្រកសត្វព្រៃណាំលៀ និងដែនជម្រកសត្វព្រៃស្រែពក និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនគ្រួសារកងទ័ព និងនគរបាលជាតិ ឈរជើងការពារតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្ដីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៤៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្ដីពីសម្បទានដីសង្គមកិច្ច
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

កាត់ផ្ទៃដីទំហំ ២៤០ (ពីររយសែសិប) ហិកតា ដែលមានចំនួន ៣ (បី) ទីតាំង ស្ថិតនៅក្នុងឃុំដាក់ដាំ ស្រុកអូររាំង ឃុំក្រង់តេះ ស្រុកពេជ្រាដា និងឃុំស្រែហ៊ុយ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ចេញពីដីតម្រប់ព្រៃឈើឆ្នាំ ២០០២ ដែនជម្រកសត្វព្រៃណាំលៀ និងដែនជម្រកសត្វព្រៃស្រែពក និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដូចមានផែនទីបង្ហាញទីតាំងជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ តាមប្រព័ន្ធកូអរដោនេ UTM Zone 48N, Datum WGS 1984 និងមាននិយាមកាដូចខាងក្រោម÷

| ទីតាំងទី ០១ | | | ទីតាំងទី ០២ | | | ទីតាំងទី ០៣ | | |
|---|---|---|---|---|---|---|---|---|
| ចំណុច | X | Y | ចំណុច | X | Y | ចំណុច | X | Y |
| 1 | 766049 | 1360469 | 1 | 777562 | 1413009 | 1 | 773310 | 1450247 |
| 2 | 766849 | 1360469 | 2 | 777560 | 1415009 | 2 | 773962 | 1452138 |
| 3 | 766849 | 1361469 | 3 | 777160 | 1415009 | 3 | 773584 | 1452269 |
| 4 | 766049 | 1361469 | 4 | 777162 | 1413009 | 4 | 772932 | 1450378 |

**មាត្រា ២.-**

ប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ និងធ្វើសម្បទានដីសង្គមកិច្ចជូនគ្រួសារកងទ័ព និងនគរបាលជាតិឈរជើងការពារតាមបណ្តោយព្រំដែន ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥ រោច ខែកត្ដិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាជិក គសសជ
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៨០ ( ប៉ែតសិប )ហិកតា

ស្ថិតនៅភូមិឡៅរមៀត ឃុំក្រង់តេះ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី

ឧបសម្ព័ន្ធអនុក្រឹត្យលេខ÷១៦៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៨




| ID | X | Y |
|---|---|---|
| 1 | 777562 | 1413009 |
| 2 | 777560 | 1415009 |
| 3 | 777160 | 1415009 |
| 4 | 777162 | 1413009 |

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៨០ ( ប៉ែតសិប ) ហិកតា

ស្ថិតនៅភូមិស្រែហ៊ុយ ឃុំស្រែហ៊ុយ ស្រុកកោះញែក ខេត្តមណ្ឌលគិរី

ឧបសម្ព័ន្ធអនុក្រឹត្យលេខ÷...១៦៤ អនក្រ.បក ចុះថ្ងៃទី...២៧... ខែ...វិច្ឆិកា.....ឆ្នាំ២០១៨




| ID | X | Y |
|---|---|---|
| 1 | 773310 | 1450247 |
| 2 | 773962 | 1452138 |
| 3 | 773584 | 1452269 |
| 4 | 772932 | 1450378 |

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៨០ ( ប៉ែតសិប ) ហិកតា

ស្ថិតនៅភូមិពូឡេះ ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី

ឧបសម្ព័ន្ធអនុក្រឹត្យលេខ÷...១៦៤ អនក្រ.បក ចុះថ្ងៃទី...២៧... ខែ...វិច្ឆិកា... ឆ្នាំ២០១៨




| ID | X | Y |
|---|---|---|
| 1 | 766049 | 1360469 |
| 2 | 766849 | 1360469 |
| 3 | 766849 | 1361469 |
| 4 | 766049 | 1361469 |